# សេចក្តីជូនដំណឹងអំពីការផ្ទេរ ឬការអនុញ្ញាតឲ្យចេញពីមណ្ឌលចាស់ជរា
# Nursing Home Transfer or Discharge Notice

ទម្រង់នេះប្រហែលជាត្រូវបានប្រើប្រាស់ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់សេចក្តីជូនដំណឹងអំពីការផ្ទេរ ឬការអនុញ្ញាតឲ្យចាកចេញដែលត្រូវបានផ្តួចផ្តើមគំនិតដោយមណ្ឌលចាស់ជរា និងមិនមែនដោយនិវាសនជន គ្រូពេទ្យ អាណាព្យាបាលស្របច្បាប់របស់និវាសនជនក្នុងនាមជាអ្នកតំណាងនោះទេ។ លក្ខខណ្ឌតម្រូវជាក់លាក់អាចស្វែងរកបាននៅក្នុង 42 CFR §483.15(c), RCW 74.42.450, WAC 388-97-0120 និង WAC 388-97-0140។ យោងតាម **42 CFR §483.15(c)(3)** សំណៅចម្លងមួយច្បាប់នៃ សេចក្តីជូនដំណឹងអំពីការផ្ទេរ ឬការអនុញ្ញាតឲ្យចាកចេញដែលត្រូវបានផ្តួចផ្តើមគំនិតដោយមណ្ឌលចាស់ជរាត្រូវតែបានផ្ញើទៅកាន់ការិយាល័យបណ្តឹងសាធារណៈផ្នែកការថែទាំរយៈពេលវែងប្រចាំរដ្ឋ។

| ព័ត៌មានអំពីនិវាសនជន | |
|---|---|
| ឈ្មោះនិវាសនជន | លេខទូរស័ព្ទ (រួមបញ្ចូលទាំងលេខកូដតំបន់ផងដែរ) |
| អាសយដ្ឋាន | |

| ព័ត៌មានអំពីមណ្ឌលចាស់ជរា | |
|---|---|
| ឈ្មោះមណ្ឌលចាស់ជរា | លេខទូរស័ព្ទ (រួមបញ្ចូលទាំងលេខកូដតំបន់ផងដែរ) |
| អាសយដ្ឋាន | |
| ឈ្មោះបុគ្គលទំនាក់ទំនង | លេខទូរស័ព្ទរបស់បុគ្គលទំនាក់ទំនង (រួមបញ្ចូលទាំងលេខកូដតំបន់ផងដែរ) |

| កាលបរិច្ឆេទប្រគល់សេចក្តីជូនដំណឹង/កាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្ត | |
|---|---|
| សម្គាល់៖ កាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្តត្រូវតែមានរយៈពេលយ៉ាងតិច 30 ថ្ងៃចាប់ពីកាលបរិច្ឆេទដែលសេចក្តីជូនដំណឹងនេះត្រូវបានប្រគល់ជូន លុះត្រាតែមានករណីលើកលែងណាមួយត្រូវបានអនុវត្តដោយយោងតាម WAC 388-97-0120។ និវាសនជនប្រហែលជាអាចជ្រើសរើសផ្លាស់ចេញពីមណ្ឌលលឿនជាងកាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្ត។ | |
| កាលបរិច្ឆេទប្រគល់សេចក្តីជូនដំណឹង | កាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្ត (កាលបរិច្ឆេទអនុញ្ញាតឲ្យចាកចេញ) |

| ទីតាំងដែលនិវាសនជនត្រូវបានផ្ទេរទៅកាន់ ឬត្រូវបានអនុញ្ញាតឲ្យចាកចេញទៅកាន់ (តម្រូវឱ្យមាន) | |
|---|---|
| ឈ្មោះ | លេខទូរស័ព្ទ (រួមបញ្ចូលទាំងលេខកូដតំបន់ផងដែរ) |
| អាសយដ្ឋាន | |

មូលហេតុសម្រាប់ការអនុញ្ញាតឲ្យចាកចេញ ឬការផ្ទេរ

- ☐ ការផ្ទេរ ឬការអនុញ្ញាតឲ្យចាកចេញ គឺចាំបាច់សម្រាប់សុខមាលភាពរបស់អ្នក ហើយមណ្ឌលនេះមិនអាចបំពេញតាមតម្រូវការនានារបស់អ្នកបាននោះទេ។
- ☐ សុខភាពរបស់អ្នកមានភាពល្អប្រសើរជាងមុនយ៉ាងសមស្របហើយ ដូច្នេះអ្នកមិនត្រូវការសេវានានាដែលផ្តល់ជូនដោយមណ្ឌលនេះទៀតនោះទេ។
- ☐ សុវត្ថិភាពរបស់បុគ្គលដទៃទៀតនៅក្នុងមណ្ឌលនេះកំពុងតែប្រឈមនឹងគ្រោះថ្នាក់ដោយសារឋានៈរបស់និវាសនជន។
- ☐ សុខភាពរបស់បុគ្គលដទៃទៀតនៅក្នុងមណ្ឌលនេះ អាចនឹងប្រឈមនឹងគ្រោះថ្នាក់ដោយសារមូលហេតុផ្សេងទៀត។
- ☐ បន្ទាប់ពីមានសេចក្តីជូនដំណឹងយ៉ាងសមហេតុផល និងយ៉ាងសមស្រប អ្នកបានខកខានមិនបានទូទាត់ប្រាក់ (ឬមិនបានទូទាត់ប្រាក់ស្របតាម Medicare ឬ Medicaid) សម្រាប់ការស្នាក់នៅក្នុងមណ្ឌលនេះ។
- ☐ មណ្ឌលនេះកំពុងតែបិទទ្វារ។

សូមផ្តល់ការពន្យល់ត្រួសៗដើម្បីគាំទ្រដល់ចំណាត់ការនេះ។ សូមភ្ជាប់មកជាមួយនូវសំណុំឯកសារបន្ថែម ប្រសិនបើចាំបាច់។

ការស្នើសុំជំនួយ៖ ប្រសិនបើមានការស្នើសុំ មណ្ឌលត្រូវតែផ្តល់ជូននូវជំនួយដែលមានភាពចាំបាច់ក្នុងការទំនាក់ទំនងអង្គការនានាទៅទំព័របន្ទាប់ និង/ឬស្នើសុំដាក់បណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចនេះ ប្រសិនបើអ្នកមិនយល់ស្របចំពោះការផ្ទេរ ឬការអនុញ្ញាតឲ្យចាកចេញនេះ។ សូមមើលឈ្មោះ និងលេខទូរស័ព្ទរបស់បុគ្គលទំនាក់ទំនងនៃមណ្ឌលចាស់ជរា។

សិទ្ធិក្នុងការដាក់បណ្ដឹងតវ៉ា៖

- អ្នកមានសិទ្ធិដាក់បណ្ដឹងតវ៉ាចំពោះការអនុញ្ញាតឲ្យចាកចេញ ឬការផ្ទេរនេះតាមរយៈការដាក់សំណើសុំបើកសវនាការមួយទៅកាន់ការិយាល័យសវនាការរដ្ឋបាលប្រចាំរដ្ឋវ៉ាស៊ីនតោន។ សំណើស្នើសុំបើកសវនាការរបស់អ្នកអាចធ្វើឡើងនៅពេលណាមួយនៅក្នុងរយៈពេលរហូតដល់ 90 ថ្ងៃចាប់ពីកាលបរិច្ឆេទដែលអ្នកទទួលបានសេចក្ដីជូនដំណឹងនេះ។
- ប្រសិនបើអ្នកសម្រេចចិត្តដាក់បណ្ដឹងតវ៉ា អ្នកប្រហែលជាអាចស្នើសុំបើកសវនាការដោយផ្ទាល់ តាមរយៈទូរស័ព្ទ/សារជាសម្លេង ឬជាលាយលក្ខណ៍អក្សរ។ អ្នកប្រហែលជាអាចប្រើប្រាស់ទម្រង់ដែលបានភ្ជាប់មកជាមួយនេះ (DSHS 10-238, សំណើសុំបើកសវនាការរដ្ឋបាល) ដើម្បីស្នើសុំដាក់បណ្ដឹងតវ៉ា ប៉ុន្តែអ្នកមិនត្រូវបានតម្រូវឲ្យប្រើប្រាស់វានោះទេ។
- អ្នកមានសិទ្ធិស្នាក់នៅក្នុងមណ្ឌលនេះបន្តទៀតរហូតទាល់តែបណ្ដឹងតវ៉ានោះត្រូវបានធ្វើសេចក្ដីសម្រេច ប្រសិនបើសំណើសុំបើកសវនាការត្រូវបានទទួលនៅ ឬនៅមុនកាលបរិច្ឆេទនៃការផ្ទេរ/ការអនុញ្ញាតឲ្យចាកចេញដែលត្រូវបានស្នើឡើង ឬថ្ងៃដែលអ្នកត្រូវបានផ្ទេរ/ត្រូវបានអនុញ្ញាតឲ្យចាកចេញយ៉ាងពិតប្រាកដ។ ករណីលើកលែង៖ ប្រសិនបើមិនអនុញ្ញាតឲ្យអ្នកចាកចេញ ឬមិនផ្ទេរអ្នកចេញពីមណ្ឌលទេនោះនឹងអាចបង្កគ្រោះថ្នាក់ចំពោះសុខភាព ឬសុវត្ថិភាពរបស់អ្នក ឬសុខភាព ឬសុវត្ថិភាពរបស់បុគ្គលដទៃទៀតនៅក្នុងមណ្ឌល អ្នកប្រហែលជាត្រូវបានអនុញ្ញាតឲ្យចាកចេញ ឬត្រូវបានផ្ទេរចេញ។ កាលបរិច្ឆេទអនុញ្ញាតឲ្យចាកចេញ/កាលបរិច្ឆេទផ្ទេរមាននៅទំព័រខាងមុខនៃសេចក្ដីជូនដំណឹងនេះ។
- ប្រសិនបើអ្នកមិនដាក់បណ្ដឹងតវ៉ាទេនោះ មណ្ឌលចាស់ជរាប្រហែលជាអាចចាប់ផ្ដើមដំណើរការការផ្ទេរ ឬការអនុញ្ញាតឲ្យចាកចេញរបស់អ្នក។
- ប្រសិនបើសេចក្ដីសម្រេចនៅសវនការគាំទ្រចំពោះសេចក្ដីសម្រេចរបស់មណ្ឌលចាស់ជរានោះ (អ្នកចាញ់បណ្ដឹងតវ៉ា) មណ្ឌលចាស់ជរាប្រហែលជាអាចចាប់ផ្ដើមដំណើរការការផ្ទេរ ឬការអនុញ្ញាតឲ្យចាកចេញរបស់អ្នកនៅក្នុងរយៈពេល 30 ថ្ងៃក្រោយពេលដែលដីកាសម្រេចមួយដែលយល់ព្រមតាមសេចក្ដីសម្រេចនេះបានចូលជាស្ថាពរ។
- ប្រសិនបើការអនុញ្ញាតឲ្យចាកចេញ/ ការផ្ទេរមិនត្រូវបានយល់ស្របតាមទេនោះ (អ្នកឈ្នះបណ្ដឹងតវ៉ា) ហើយអ្នកឈប់ស្នាក់នៅក្នុងមណ្ឌលនេះហើយនោះ អ្នកមានសិទ្ធទទួលបាន ការអនុញ្ញាតឲ្យចូលស្នាក់នៅក្នុងមណ្ឌលនេះឡើងវិញភ្លាមៗបន្ទាប់ពីមានគ្រែទំនេរទីមួយនៅក្នុងបន្ទប់ពាក់កណ្ដាលឯកជននៅក្នុងលក្ខខណ្ឌដែលអ្នកត្រូវការ និងមានសិទ្ធទទួលបានសេវានានាដែលផ្ដល់ជូនដោយមណ្ឌលនេះ។

ផ្ញើសំណើសុំបើកសវនាការទៅកាន់៖ OFFICE OF ADMINISTRATIVE HEARINGS

PO BOX 42489
OLYMPIA WA  98504-2489
លេខទូរស័ព្ទ៖ 1-800-583-8271
ទូរសារ៖ (360) 586-6563

ការិយាល័យបណ្ដឹងសាធារណៈប្រចាំរដ្ឋវ៉ាស៊ីនតោន៖

កម្មវិធីបណ្ដឹងសាធារណៈការថែទាំរយៈពេលវែងរដ្ឋវ៉ាស៊ីនតោនគឺអាចរកបានសម្រាប់ឆ្លើយសំណួរផ្សេងៗ និងផ្ដល់ជំនួយ ទាក់ទងនឹងសេចក្ដីជូនដំណឹងនេះ និងបញ្ហាដទៃទៀត។ តាមរយៈការងាររបស់បុគ្គលម្នាក់ៗ "LTC Ombuds" កម្មវិធីបណ្ដឹងសាធារណៈការពារ និងលើកកម្ពស់សិទ្ធិស្របច្បាប់របស់អ្នករស់នៅដែលរស់នៅក្នុងមណ្ឌល LTC។ កម្មវិធីបណ្ដឹងសាធារណៈគឺមិនមែនជាផ្នែកនៃរដ្ឋាភិបាលរដ្ឋ និងមិនមែនជាសាខារបស់មណ្ឌលថែទាំរយៈពេលវែងណាមួយឡើយ។ ប្រសិនបើអ្នកចង់ស្នើសុំជំនួយពី LTC Ombudsសូមហៅទូរស័ព្ទឥតគិតថ្លៃតាមលេខ 1-800-562-6028។ អ្នកក៏អាចធ្វើការស្នើសុំរបស់អ្នកជាលាយលក្ខណ៍អក្សរបានផងដែរដោយផ្ញើទូរសារតាមលេខ (253) 815-8173 ផ្ញើអ៊ីម៉ែលទៅ ltcop@mschelps.org ឬផ្ញើសំបុត្រទៅ PO Box 23699, Federal Way, WA 98093-0699។

ផ្នែកសិទ្ធិរបស់ជនពិការនៃរដ្ឋវ៉ាស៊ីនតោន៖

ប្រសិនបើអ្នកមានរោគវិនិច្ឆ័យអំពីជំងឺផ្នែកខួរក្បាលណាមួយ ឬមានពិការភាពផ្នែកបញ្ញា អ្នកប្រហែលជាអាចទាក់ទងផ្នែកសិទ្ធិរបស់ជនពិការនៃរដ្ឋវ៉ាស៊ីនតោន ដើម្បីទទួលបានជំនួយនៅក្នុងការដាក់បណ្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចនេះ អ្នកអាចហៅទូរស័ព្ទដោយឥតគិតថ្លៃទៅកាន់លេខ 1-800-562-2702 ឬ (206) 324-1521។ អ្នកក៏ប្រហែលជាអាចដាក់សំណើរបស់អ្នកជាលាយលក្ខណ៍អក្សរតាមរយៈទូរសារទៅកាន់លេខ (206) 957-0729 អ៊ីមែលទៅកាន់ info@dr-wa.org ឬផ្ញើសំបុត្រទៅកាន់ផ្នែកសិទ្ធិរបស់ជនពិការនៃរដ្ឋវ៉ាស៊ីនតោន Disability Rights Washington, 315 5th Avenue S, Suite 850, Seattle, WA, 98104 បានផងដែរ។

សេចក្ដីជូនដំណឹងត្រូវបានបង្ហាញដោយ៖

| ហត្ថលេខារបស់បុគ្គលិកផ្នែករដ្ឋបាលនៃមណ្ឌលចាស់ជរា/បុគ្គលដែលត្រូវបានចាត់តាំង | កាលបរិច្ឆេទ | ឈ្មោះជាអក្សរពុម្ព |
|---|---|---|

សេចក្ដីជូនដំណឹងត្រូវបានប្រគល់ជូន៖

| ឈ្មោះជាអក្សរពុម្ពរបស់និវាសនជន ឬអ្នកតំណាងរបស់និវាសនជន | កាលបរិច្ឆេទ |
|---|---|